**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ..៣១...អនក្រ.បក**

**អនុក្រឹត្យ**

**ស្ដីពី**

**ការធ្វើអនុបយោគដីបឹងខ្វែងទំហំ ៧ ហិកតា ៤៩ អា និង ៧៦ សង់ទីអា ស្ថិតនៅស្រុកពញាឮ ខេត្តកណ្ដាល ពីដីសាធារណៈរបស់រដ្ឋ មកជាដីឯកជនរបស់រដ្ឋ និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៣៨ គ្រួសារ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១ .-**

ធ្វើអនុបយោគដីបឹងខ្វែងទំហំ ៧ ហិកតា ៤៩ អា និង ៧៦ សង់ទីអា ស្ថិតនៅភូមិព្រៃកតាព្រហ្ម ឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល ពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៣៨ គ្រួសារ នូវចំណែកស្មើៗគ្នា។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៩កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទីនិងតារាងនិយាមការឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៣៦.អនក្រ.បក. ចុះថ្ងៃទី..៦........ខែ.កុម្ភៈ...ឆ្នាំ២០២២




តារាងនិយាមការចំណុចព្រំដី

Projection UTM, Zone48N, Datum WGS84

| Point_ID | Northing (m) | Easting (m) |
|---|---|---|
| 1 | 484274.976 | 1291968.823 |
| 2 | 484248.994 | 1291973.925 |
| 3 | 484234.339 | 1291998.274 |
| 4 | 484227.871 | 1292013.113 |
| 5 | 484205.327 | 1292055.975 |
| 6 | 484194.277 | 1292075.278 |
| 7 | 484181.464 | 1292098.943 |
| 8 | 484170.002 | 1292119.823 |
| 9 | 484157.995 | 1292144.360 |
| 10 | 484141.008 | 1292166.070 |
| 11 | 484145.203 | 1292168.575 |
| 12 | 484184.364 | 1292195.684 |
| 13 | 484157.203 | 1292246.356 |
| 14 | 484200.626 | 1292282.224 |
| 15 | 484221.109 | 1292295.062 |
| 16 | 484288.654 | 1292332.784 |
| 17 | 484356.577 | 1292371.140 |
| 18 | 484454.935 | 1292253.966 |
| 19 | 484436.422 | 1292200.702 |
| 20 | 484414.245 | 1292130.282 |
| 21 | 484408.986 | 1292114.089 |
| 22 | 484397.566 | 1292090.782 |
| 23 | 484386.080 | 1292075.323 |
| 24 | 484361.004 | 1292062.888 |
| 25 | 484350.916 | 1292052.104 |
| 26 | 484339.394 | 1292031.292 |
| 27 | 484326.724 | 1292010.787 |
| 28 | 484312.102 | 1291988.507 |
| 29 | 484292.211 | 1291978.105 |

## ប្លង់បង្ហាញទីតាំងដីបឹងខ្វែងទំហំ ៧៤ ៩៧៦ ម៉ែត្រក្រឡា ស្ថិតនៅភូមិព្រែកតាព្រហ្ម ឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល ស្នើសុំចុះបញ្ជីដោយប្រជាពលរដ្ឋចំនួន ២៣៨ គ្រួសារ




តារាងនិយាមការចំណុចព្រំដី

Projection UTM, Zone48N, Datum WGS84

| Point_ID | Northing (m) | Easting (m) |
|---|---|---|
| 1 | 484274.976 | 1291968.823 |
| 2 | 484248.994 | 1291973.925 |
| 3 | 484234.339 | 1291998.274 |
| 4 | 484227.871 | 1292013.113 |
| 5 | 484205.327 | 1292055.975 |
| 6 | 484194.277 | 1292075.278 |
| 7 | 484181.464 | 1292098.943 |
| 8 | 484170.002 | 1292119.823 |
| 9 | 484157.995 | 1292144.360 |
| 10 | 484141.008 | 1292166.070 |
| 11 | 484145.203 | 1292168.575 |
| 12 | 484184.364 | 1292195.684 |
| 13 | 484157.203 | 1292246.356 |
| 14 | 484200.626 | 1292282.224 |
| 15 | 484221.109 | 1292295.062 |
| 16 | 484288.654 | 1292332.784 |
| 17 | 484356.577 | 1292371.140 |
| 18 | 484454.935 | 1292253.966 |
| 19 | 484436.422 | 1292200.702 |
| 20 | 484414.245 | 1292130.282 |
| 21 | 484408.986 | 1292114.089 |
| 22 | 484397.566 | 1292090.782 |
| 23 | 484386.080 | 1292075.323 |
| 24 | 484361.004 | 1292062.888 |
| 25 | 484350.916 | 1292052.104 |
| 26 | 484339.394 | 1292031.292 |
| 27 | 484326.724 | 1292010.787 |
| 28 | 484312.102 | 1291988.507 |
| 29 | 484292.211 | 1291978.105 |